# របាយការណ៍ស្តីអំពី ការជួញដូរមនុស្ស ឆ្នាំ២០០៤

## ការអត្ថាធិប្បាយ លើប្រទេសនីមួយ

### ប្រទេសកម្ពុជា (ចំណាត់ថ្នាក់លេខ២)

ប្រទេសកម្ពុជាគឺជាប្រទេសដែលបញ្ជូន ទទួលយក និងជាច្រកឆ្លងកាត់សំរាប់អ្នកដែលត្រូវគេជួញដូរ ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងធ្វើការងារដោយបង្ខិតបង្ខំ ។ បុរស ស្ត្រី និងកុមារកម្ពុជាត្រូវបានគេជួញដូរទៅ ប្រទេសថៃ និងម៉ាឡេស៊ីដើម្បីធ្វើការងារដោយបង្ខិតបង្ខំ និងធ្វើជាពេស្យាចារ ។ មិនតែប៉ុណ្ណោះ កុមារកម្ពុជា នៅត្រូវបានគេជួញដូរទៅកាន់ប្រទេសវៀតណាមនិងប្រទេសថៃដើម្បីធ្វើជាអ្នកសុំទានតាមចិញ្ចើមថ្នល់ទៀត ផង ។ ប្រទេសកម្ពុជាគឺជាច្រកឆ្លងកាត់ និងចំនុចទទួលយកស្ត្រីដែលត្រូវបានគេជួញដូរពីប្រទេសវៀតណាម ហើយត្រូវបង្ខំអោយធ្វើជាពេស្យាចារ ។ មិនមានការប៉ាន់ប្រមាណដែលអាចជឿជាក់បានណាមួយអំពីជំរៅ និងវិសាលភាពនៃបញ្ហានេះឡើយ ។ រដ្ឋាភិបាលកម្ពុជាមិនបានបំពេញអោយបានខ្ជាប់ខ្ជួនទៅតាមក៏រិតស្តង់ដារ អប្បរមាក្នុងការលុបបំបាត់ការជួញដូរមនុស្សឡើយ ក៏ប៉ុន្តែបានបង្ហាញនូវការខិតខំប្រឹងប្រែងគួរអោយកត់ សំគាល់ដើម្បីលុបបំបាត់ ទោះបីជានៅមានកង្វះខាតផ្នែកធនធានជាច្រើនក៏ដោយ ។ មន្ត្រីរដ្ឋាភិបាលបានទទួល ស្គាល់ថា ការជួញដូរគឺជាបញ្ហាដ៏ធំមួយ ។ នៅឆ្នាំ២០០៣ អាជ្ញាធរកម្ពុជាបានបង្កើនការចាប់ខ្លួន និងកាត់ទោស អ្នកជួញដូរមនុស្ស ។ ដោយមានការសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ហើយនិង អង្គការអន្តរជាតិមួយចំនួន ប្រទេសកម្ពុជាបានបន្តផ្តល់ការគាំទ្ររបស់ខ្លួនដល់កម្មវិធីសំរាប់ការទប់ស្កាត់ និង ការពារ ។ ទោះជាយ៉ាងនេះក៏ដោយ ការខិតខំរបស់ប្រទេសកម្ពុជាក្នុងការប្រឆាំងនឹងការជួញដូរនៅតែត្រូវបាន រារាំងដោយអំពើពុករលួយ និងប្រព័ន្ធតុលាការដែលមិនមានប្រសិទ្ធភាព ។ មន្ត្រីរបស់រដ្ឋាភិបាលកម្ពុជា និង សមាជិកគ្រួសាររបស់គេ ត្រូវបានគេរាយការណ៍ថាមានជាប់ពាក់ព័ន្ធ រឺបានទទួលប្រាក់ចំនេញពីសកម្មភាព ជួញដូរមនុស្ស ។ សកម្មភាពរបស់រដ្ឋាភិបាលគួរតែផ្តោតលើការពង្រីកសមត្ថភាពក្នុងការបង្ក្រាបការជួញដូរ នៅគ្រប់លំដាប់ថ្នាក់ និងបញ្ឈប់ពីការងារនូវមន្ត្រីអនុវត្តច្បាប់ និងសមាជិកក្នុងប្រព័ន្ធតុលាការទាំងឡាយណា ដែលមានការពាក់ព័ន្ធ រឺទទួលប្រាក់ចំនេញពីការជួញដូរនោះ ។

## ការចោទប្រកាន់ទោស

ប្រទេសកម្ពុជាមិនមានច្បាប់ប្រឆាំងការជួញដូរដែលលំអិតមួយទេ ប៉ុន្តែបានប្រើប្រាស់ច្បាប់ដែលមានស្រាប់សំរាប់កាត់ទោសអ្នកជួញដូរមនុស្ស ។ ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីកំពុងតែពិនិត្យលើពង្រៀងច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស ដែលអាចអោយមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីយុត្តិធម៌មានអំណាចច្រើនជាងមុនក្នុងការចាប់ខ្លួន និងធ្វើការចោទប្រកាន់អ្នកជួញដូរ ។ យោងតាមឯកសារដែលមានស្រាប់បានអោយដឹងថា នៅក្នុងឆ្នាំង២០០៣ នគរបាលកម្ពុជាបានធ្វើការស្រាវជ្រាវលើករណីដែលទាក់ទងនឹងការជួញដូរចំនួន៤០០ ករណី ។ ក្រសួងមហាផ្ទៃបានអះអាងថា មានមនុស្សចំនួន១៥៣នាក់ត្រូវបានចាប់ខ្លួនពីបទជួញដូរ និងបទល្មើសដទៃទៀតដែលពាក់ព័ន្ធនឹងការជួញដូរ ។ ក្នុងចំនោមនោះ មាន១៤២នាក់កំពុងជាប់ទោសក្នុងពន្ធនាគារ ហើយ១១នាក់ទៀតកំពុងរង់ចាំការកាត់ទោស ។ ការដាក់ទោសអោយជាប់ពន្ធនាគារមានពី៥ឆ្នាំទៅ២០ឆ្នាំ ។ ជនរងគ្រោះបានទទួលនូវសំណងជាទឹកប្រាក់តិចតួចស្តួចស្តើងតាមរយៈតុលាការ ។ អំពើពុករលួយ និងប្រព័ន្ធតុលាការដែលទន់ខ្សោយ នៅតែជាឧបសគ្គចំបងក្នុងការកាត់ទោសអ្នកជួញដូរអោយមានប្រសិទ្ធិភាព ។ អាជ្ញាធរកម្ពុជា ជាពិសេសប៉ូលីសប្រឆាំងការជួញដូរ បានសហការជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងការចាប់ និងប្រគល់ខ្លួនពលរដ្ឋអាមេរិក៣រូប ដើម្បីអោយទទួលការចោទប្រកាន់ពីបទល្មើសធ្វើទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងប្រទេសដទៃ ដែលមានចែងនៅក្នុងច្បាប់ PROTECT Act. ។ ការចាប់ខ្លួនមួយក្នុងចំនោមការចាប់ខ្លួនទាំងនេះ បានក្លាយជាការផ្តន្ទាទោសដំបូងបំផុតរបស់អាមេរិកតាមច្បាប់ PROTECT Act. ។ ប្រទេសកម្ពុជានៅបានសហការផងដែរជាមួយនឹងរដ្ឋាភិបាលប្រទេសដទៃទៀត ដែលព្យាយាមធ្វើការកាត់ទោសប្រជាជនរបស់ខ្លួនដែលបានកេងប្រវ័ញ្ចលើផ្លូវភេទកុមារ ។

## ការការពារ

ទោះបីជាត្រូវរារាំងដោយការខ្វះខាតផ្នែកធនធានដ៏ធ្ងន់ធ្ងរក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាបានបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការផ្តល់ជំនួយដល់ជនរងគ្រោះដោយការជួញដូរដែរ ។ រាជរដ្ឋាភិបាលកម្ពុជាបានដំណើរការកន្លែងស្នាក់នៅបណ្តោះអាសន្នចំនួន២សំរាប់ជនរងគ្រោះ និងមានគំរោងបញ្ជូនជនរងគ្រោះទៅអង្គការក្រៅរដ្ឋាភិបាល ដើម្បីបានស្នាក់នៅរយៈពេលយូរ ។ រដ្ឋាភិបាលកម្ពុជាពឹងផ្អែកជាចំបងលើអង្គការក្រៅរដ្ឋាភិបាលក្នុងនិងក្រៅស្រុក ក្នុងការផ្តល់សេវាកម្មការពារដល់ជនរងគ្រោះទាំងនោះ ។ នៅក្នុងប្រទេសកម្ពុជា ជនរងគ្រោះមិនត្រូវបានគេចាត់ទុកថាជាជនល្មើសទេ ហើយពួកគេមានសិទ្ធិក្នុងការស្វែងរកសកម្មភាពតាមផ្លូវ

ច្បាប់ដើម្បីប្រឆាំងនឹងអ្នកជួញដូរ ។ នៅឆ្នាំ២០០៣ កម្ពុជាបានចុះហត្ថលេខាលើអនុសារណៈនៃការយោគយល់មួយជាមួយនឹងប្រទេសថៃ ដើម្បីធ្វើអោយមានច្បាប់ទំលាប់ក្នុងការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋរីជនរងគ្រោះកម្ពុជា ។ កម្ពុជាបានស្នើរអោយមានអនុសារណៈនៃការយោគយល់បែបនេះដែរជាមួយនឹងប្រទេសវៀតណាម និងម៉ាឡេស៊ី ។ មន្រ្តីអនុវត្តច្បាប់ បានទទួលការបណ្តុះបណ្តាលដើម្បីធ្វើអោយពួកគេលើកកំពស់ការភ្ញាក់រលឹកចំពោះបញ្ហាទាក់ទិននឹងការជួញដូរនិងការការពារជនរងគ្រោះ ។

## ការទប់ស្កាត់

ក្នុងរយៈពេលធ្វើរបាយការណ៍នេះ រដ្ឋាភិបាលបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិមួយចំនួនក្នុងការទប់ស្កាត់ ដោយរួមបញ្ចូលទាំងការពង្រឹងបណ្តាញតាមសហគមន៍ដើម្បីប្រាប់ដល់អ្នកដែលអាចក្លាយជាជនរងគ្រោះ អំពីលទ្ធភាពនៃការជួញដូរ ។ រដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន បានបន្តធ្វើយុទ្ធនាការពតិមាន ក្នុងនោះមានការជួបជុំរបស់ប្រជាពលរដ្ឋនៅតាមខេត្តសំខាន់៧ផងដែរ ។ រដ្ឋាភិបាលថែមទាំងបានធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលដើម្បីរៀបចំសិក្ខាសាលាផលិតកូនសៀវភៅ និងខ្សែវីដេអូ ដើម្បីប្រាប់ដល់សាធារណជនអំពីគ្រោះថ្នាក់នៃទេសចរណ៍ផ្លូវភេទ រួមទាំងទេសចរណ៍ផ្លូវភេទលើកុមារផងដែរ ។